# ការណែនាំ



## អំពីរបៀបបោះឆ្នោតតាមរយៈសន្លឹកឆ្នោតសម្រាប់ ពលរដ្ឋអវត្តមាន

**អ្នកចាំបាច់ត្រូវការ៖**

- សន្លឹកឆ្នោត*
- ស្រោមសំបុត្រសន្លឹកឆ្នោតពណ៌ដាំដែង*
- ពាក្យស្នើសុំចុះឈ្មោះអ្នកបោះឆ្នោត*
- ស្រោមសំបុត្រហត្ថលេខាពណ៌ស*
- ស្រោមសំបុត្រប្រគល់ពណ៌សធំ*
- ប៊ិចទឹកខ្មៅ
- ប័ណ្ណបើកបរ Minnesota ដែលមាន អាសយដ្ឋាន ឬភ័ស្តុតាងដែលបានអនុញ្ញាត ផ្សេងទៀតដែលបញ្ជាក់អំពីទីកន្លែងរស់នៅ របស់អ្នក។ *សូមមើលទំព័រខ្នងទៀតសម្រាប់បញ្ជីជម្រើសនានា*

* ប្រសិនបើពុំមានសម្ភារទាំងនេះទេ សូមទាក់ទង មកមន្ត្រីបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នក។

- លេខអត្តសញ្ញាណរបស់អ្នក
  លេខប័ណ្ណបើកបរ Minnesota លេខអត្តសញ្ញាណប័ណ្ណ Minnesota ឬ លេខសន្តិសុខសង្គមរបស់អ្នកបួនខ្ទង់ ចុងក្រោយ។ *សូមមើលខាងក្រោម ប្រសិនបើអ្នកពុំមានលេខណាមួយទេ។*
- សាក្សី
  អ្នកដែលបានចុះឈ្មោះបោះឆ្នោតនៅ Minnesota *រួមទាំងប្តី/ប្រពន្ធ ឬសាច់ញាតិរបស់អ្នក*
  ឬ សាការី
  ឬ បុគ្គលដែលមានសិទ្ធិរៀបចំការស្បថ

**ព័ត៌មានសំខាន់៖ អ្នកត្រូវដាក់ពាក្យស្នើសុំចុះឈ្មោះ បោះឆ្នោតជាមួយសន្លឹកឆ្នោតរបស់អ្នក (នៅក្នុងស្រោម សំបុត្រហត្ថលេខាពណ៌ស) ដើម្បីឱ្យគេរាប់សន្លឹកឆ្នោត របស់អ្នក។**




### ❶ បំពេញពាក្យស្នើសុំចុះឈ្មោះអ្នកបោះឆ្នោត និងចុះហត្ថលេខា

- បង្ហាញសាក្សីរបស់អ្នកនូវប័ណ្ណបើកបររបស់អ្នក ឬភ័ស្តុតាងដែលបានអនុញ្ញាតផ្សេងទៀត ដែលបញ្ជាក់អំពីទីកន្លែងរស់នៅរបស់អ្នក។ *សូមមើលខាងក្រោមប្រសិនបើអ្នកពុំមានលេខណាមួយទេ។*




### ❷ បោះឆ្នោត!

- បង្ហាញដល់សាក្សីនូវសន្លឹកឆ្នោតមិនទាន់គូស របស់អ្នក បន្ទាប់មកគូសសន្លឹកឆ្នោតរបស់អ្នក ដោយខ្លួនឯង។
- អនុវត្តតាមការណែនាំនៅលើសន្លឹកឆ្នោត
- សូមកុំសរសេរឈ្មោះ ឬលេខអត្តសញ្ញាណ របស់អ្នកនៅកន្លែងណាមួយលើសន្លឹកឆ្នោត។
- សូមកុំបោះឆ្នោតឱ្យបេក្ខជនច្រើនជាងចំនួន ដែលបានអនុញ្ញាត។ *ប្រសិនបើអ្នកបោះឆ្នោតឱ្យបេក្ខជនច្រើនជាងចំនួន ដែលបានអនុញ្ញាត នោះសន្លឹកឆ្នោត របស់អ្នកសម្រាប់ការិយាល័យនោះនឹងមិនត្រូវ បានរាប់ឡើយ។ សូមមើលទំព័រខ្នងទៀតប្រសិនបើអ្នកគូស សន្លឹកឆ្នោតខុស។*




### ❸ ដាក់សន្លឹកឆ្នោតរបស់អ្នកនៅក្នុងស្រោមសំបុត្រ សន្លឹកឆ្នោតពណ៌ដាំដែង

- សូមកុំសរសេរនៅលើស្រោមសំបុត្រ

### ❹ ដាក់ស្រោមសំបុត្រសន្លឹកឆ្នោតពណ៌ដាំដែង និងពាក្យស្នើសុំចុះឈ្មោះអ្នកបោះឆ្នោតទៅក្នុង ស្រោមសំបុត្រហត្ថលេខាពណ៌ស




### ❺ បំពេញស្រោមសំបុត្រហត្ថលេខាពណ៌សឱ្យបាន <u>គ្រប់កន្លែង</u>

- ប្រសិនបើពុំមានស្លាកទេ សូមដាក់ឈ្មោះ និង អាសយដ្ឋាននៅ Minnesota របស់អ្នក។
- ដាក់លេខប័ណ្ណបើកបរ Minnesota លេខអត្តសញ្ញាណប័ណ្ណ Minnesota ឬលេខ សន្តិសុខសង្គមបួនខ្ទង់ចុងក្រោយរបស់អ្នក។
  **សូមប្រាកដថាបានប្រើប្រាស់លេខដូចគ្នាដែល អ្នកបានផ្តល់នៅលើពាក្យស្នើសុំសន្លឹកឆ្នោតសម្រាប់ពលរដ្ឋអវត្តមាន។**
  *ប្រសិនបើអ្នកពុំមានលេខណាមួយទេ សូមពិនិត្យមើលប្រអប់។*
- អាន និងចុះហត្ថលេខាលើពាក្យស្បថ
- ឱ្យសាក្សីរបស់អ្នកដាក់ឈ្មោះរបស់គាត់ និង អាសយដ្ឋានផ្លូវ Minnesota រួមទាំងទីក្រុង (មិនមែនប្រអប់សំបុត្រ) បង្ហាញភ័ស្តុតាងណាមួយដែលអ្នកបានបង្ហាញគាត់ រួចចុះហត្ថលេខាដាក់ឈ្មោះរបស់គាត់។
  *ប្រសិនបើសាក្សីរបស់អ្នកគឺជាមន្ត្រី ឬសាការី ពួកគាត់ត្រូវដាក់មុខតំណែងជំនួសឱ្យអាសយដ្ឋាន។ សាការីត្រូវបោះត្រារបស់គាត់ផងដែរ។*
- បិទស្រោមសំបុត្រ




### ❻ ដាក់ស្រោមសំបុត្រហត្ថលេខាទៅក្នុងស្រោមសំបុត្រ ប្រគល់ពណ៌សធំដើម្បីការពារកុំឱ្យគេឃើញព័ត៌មាន ឯកជនរបស់អ្នក

- បិទស្រោមសំបុត្រ




### ❼ ប្រគល់សន្លឹកឆ្នោតរបស់អ្នក<u>នៅត្រឹមថ្ងៃបោះឆ្នោតទៅ អាសយដ្ឋាននៅលើស្រោមសំបុត្រប្រគល់</u> សន្លឹកឆ្នោតអាចនឹងមិនបញ្ជូនទៅកន្លែងបោះឆ្នោត។

អ្នកមានជម្រើសបី៖

- បញ្ជូនសន្លឹកឆ្នោតឱ្យទាន់ថ្ងៃបោះឆ្នោត ដោយ ប្រើប្រាស់សេវាបញ្ជូនសំបុត្រអាមេរិក ឬសេវា បញ្ជូនកញ្ចប់បញ្ញើ
- ប្រគល់សន្លឹកឆ្នោតដោយផ្ទាល់មុនថ្ងៃបោះឆ្នោតឬ នៅត្រឹមម៉ោង 3:00ល្ងាចនៅថ្ងៃបោះឆ្នោត។
- ឱ្យនរណាម្នាក់ប្រគល់សន្លឹកឆ្នោតនៅត្រឹមម៉ោង 3:00ល្ងាចនៅថ្ងៃបោះឆ្នោត។
  *បុគ្គលនេះមិនអាចប្រគល់សន្លឹកឆ្នោតលើសពី3ឡើយ។*




**ដើម្បីពិនិត្យមើលសន្លឹកឆ្នោតសម្រាប់ពលរដ្ឋអវត្តមាន សូមចូលទៅកាន់វែបសាយត៍ www.mnvotes.org.**

## ជម្រើសសម្រាប់ភស្តុតាងអំពីទីកន្លែងដែលអ្នករស់នៅ

ប័ណ្ណបើកបរ Minnesota ដែលមានសុពលភព អត្តសញ្ញាណប័ណ្ណ Minnesota ឬលិខិតអនុញ្ញាត បើកបរដែលមានអាសយដ្ឋានបច្ចុប្បន្នរបស់អ្នក ឬ អត្តសញ្ញាណរូបថតដែលពុំមានអាសយដ្ឋានបច្ចុប្បន្ន របស់អ្នក រួមជាមួយនឹងឯកសារដែលមានអាសយដ្ឋាន បច្ចុប្បន្នរបស់អ្នក

- **អត្តសញ្ញាណរូបថតស្របច្បាប់៖** ប័ណ្ណបើកបរ Minnesota ឬរដ្ឋផ្សេងទៀត លិខិតអនុញ្ញាតរៀន បើកបរ ឬអត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែនអាមេរិក។ អត្តសញ្ញាណប័ណ្ណយោធា ឬយោធាចូលនិវត្តន៍ អាមេរិក ប័ណ្ណសម្គាល់សិស្សអនុវិទ្យាល័យ/វិទ្យាល័យ/សាកលវិទ្យាល័យ Minnesota ឬ អត្តសញ្ញាណប័ណ្ណ សម្គាល់កុលសម្ព័ន្ធដែលមានហត្ថលេខារបស់អ្នក មកពីកុលសម្ព័ន្ធដែលទទួលស្គាល់ដោយការិយាល័យកិច្ចការឥណ្ឌា )BIA)។
- **ឯកសារស្របច្បាប់ដែលមានអាសយដ្ឋានបច្ចុប្បន្នរបស់អ្នក៖** វិក្កយបត្រច្បាប់ដើម ដែលរួមមាន របាយការណ៍គណនេយ្យ និងលិខិតជូនដំណឹងអំពីការចាប់ផ្តើមសេវាដែលមានចុះហត្ថលេខា នៅក្នុងរយៈពេល30ថ្ងៃមុន ឬដែលមានរយៈពេល កំណត់30ថ្ងៃមុន ឬក្រោយថ្ងៃបោះឆ្នោត។ របាយការណ៍តម្លៃសិក្សាបច្ចុប្បន្ន។ ឬកិច្ចសន្យា ជួលផ្ទះប្រសិនបើមានសុពលភាពរហូតដល់ថ្ងៃបោះឆ្នោត។ វិក្កយបត្រស្របច្បាប់មាន៖ ហ្គាស អគ្គិសនី កាកសំណល់រឹង ទឹក លូ ទូរស័ព្ទ ទូរស័ព្ទដៃ ទូរទស្សន៍ អ៊ីនធឺណិត ប័ណ្ណឥណទាន ឬសេវាធនាគារ ឬវិក្កយបត្រសម្រាប់បង់ថ្លៃឈ្នួល ឬបញ្ចាំ។

ឬ ឯកសារណាមួយខាងក្រោម៖

- បង្កាន់ដៃពណ៌លឿងសម្រាប់អាជ្ញាប័ណ្ណ Minnesota ដែលសុពលភាព អត្តសញ្ញាណ ប័ណ្ណ Minnesota ឬប័ណ្ណអនុញ្ញាតបើកបរ ដែលមានអាសយដ្ឋានបច្ចុប្បន្នរបស់អ្នក
- ការផ្តល់សក្ខីបត្រ៖ ហត្ថលេខារបស់អ្នកបោះឆ្នោតដែលបាន ចុះបញ្ជីដែលរស់នៅក្នុងតំបន់របស់ អ្នក និង បានដឹងថាអ្នករស់នៅក្នុងតំបន់នោះ។ ប្រសិនបើសាក្សីរបស់អ្នកត្រូវបានចុះឈ្មោះបោះឆ្នោតនៅក្នុងតំបន់នេះ សាក្សីរបស់ អ្នកអាចធានាជូនអ្នកបាន។ *បុគ្គលនេះត្រូវបំពេញ និងចុះហត្ថលេខាលើទម្រង់សក្ខីបត្រនៅផ្នែកខាងក្រោយនៃពាក្យស្នើសុំចុះឈ្មោះអ្នកបោះឆ្នោត។*
- អត្តសញ្ញាណប័ណ្ណសម្គាល់កុលសម្ព័ន្ធដែលមានឈ្មោះ អាសយដ្ឋាន ហត្ថលេខា និងរូបថត របស់អ្នកពីកុលសម្ព័ន្ធដែលទទួលស្គាល់ដោយ BIA
- "លិខិតជូនដំណឹងអំពីការចុះឈ្មោះយឺត" ប្រសិនបើអ្នកបានទទួលពីសវនករស្រុក ឬស្មៀនក្រុង
- ប្រសិនបើអ្នកបានផ្លាស់ទីលំនៅនៅក្នុងតំបន់ ឬបានប្តូរឈ្មោះ បញ្ជីឈ្មោះបច្ចុប្បន្ននៅក្នុង តំបន់
- ការចេញសក្ខីបត្រសម្រាប់ពលរដ្ឋនៃអគារស្នាក់នៅជាក់លាក់៖ ហត្ថលេខារបស់បុគ្គលិកនៃអគារស្នាក់នៅរបស់ អ្នក រួមទាំងអគារថែទាំ ផ្ទះស្នាក់នៅជាក្រុម ជម្រកសម្រាប់ស្ត្រីរងគ្រោះ ជម្រកសម្រាប់ ពលរដ្ឋគ្មានផ្ទះសម្បែង។ល។ ប្រសិនបើអ្នកមិនច្បាស់ថាតើទីកន្លែងរស់នៅដែលអ្នករស់នៅមានសិទ្ធិដែលកំណត់ដោយច្បាប់ឬទេ សូមទូរស័ព្ទសាកសួរមន្ត្រីបោះឆ្នោតនៅក្នុងមូលដ្ឋានរបស់អ្នក។ បុគ្គលិកត្រូវបំពេញ និងចុះហត្ថលេខានៅលើសក្ខីបត្រ នៅទំព័រក្រោយនៃពាក្យស្នើសុំចុះឈ្មោះអ្នកបោះឆ្នោត។

---

## ការកែប្រែកំហុស




- ប្រសិនបើមានពេល សូមស្នើសុំសន្លឹកឆ្នោតថ្មីពី ការិយាល័យបោះឆ្នោតរបស់អ្នក។ ឬ
- គូសចោលឈ្មោះបេក្ខជនដែលអ្នកច្រឡំគូស រួច បន្ទាប់មកគូសយកឈ្មោះបេក្ខជនដែលអ្នកពេញចិត្ត (សូមកុំចុះហត្ថលេខាសង្ខេបនៅលើកន្លែង កែរបស់អ្នក)។

---

## ប្រសិនបើអ្នកជាជនពិការ៖

ប្រសិនបើអ្នកជាជនពិការ ឬមិនអាចគូសសន្លឹកឆ្នោត របស់អ្នកបាន សាក្សីរបស់អ្នកអាចជួយគូសសន្លឹក ឆ្នោតទៅតាមការណែនាំរបស់អ្នក រៀបចំឯកសារ និងបំពេញបែបបទជូនអ្នក។

នៅពេលចុះហត្ថលេខាលើស្រោមសំបុត្រ ច្បាប់ Minnesota ចែងថា អ្នកអាច៖

- ចុះហត្ថលេខានៅលើស្រោមសំបុត្រប្រគល់ដោយខ្លួនអ្នកផ្ទាល់ ឬ
- គូសសន្លឹកឆ្នោតដោយខ្លួនឯង ឬ
- សុំឱ្យសាក្សីរបស់អ្នកជួយចុះហត្ថលេខាជំនួសអ្នក នៅចំពោះមុខអ្នក។ (ឱ្យសាក្សីចុះហត្ថលេខាដាក់ ឈ្មោះរបស់គាត់ផងដែរ)។
- ប្រសិនបើអ្នកបានប្រើប្រាស់ត្រាហត្ថលេខាសម្រាប់ ការចុះហត្ថលេខាទាំងអស់ អ្នកអាចប្រើប្រាស់ត្រា ហត្ថលេខារបស់អ្នក ឬសុំឱ្យសាក្សីរបស់ អ្នកប្រើប្រាស់ត្រាហត្ថលេខារបស់អ្នកនៅចំពោះមុខ អ្នក។

លក្ខខន្តិក: Minnesota Statutes ផ្នែក 645.44អនុផ្នែក 14

កំណត់សម្គាល់៖ លិខិតផ្ទេរសិទ្ធិមិនអាចប្រើប្រាស់ នៅក្នុងការបោះឆ្នោតឡើយ។ បុគ្គលដែលមានលិខិត ផ្ទេរសិទ្ធិអាចត្រឹមតែចុះហត្ថលេខាជំនួសអ្នក នៅចំពោះមុខអ្នកតែប៉ុណ្ណោះ ដូចដែលបានលើកឡើង ខាងលើ។

---

**កំណត់សម្គាល់អំពីការរក្សាការសម្ងាត់៖** ប្រសិនបើ សន្លឹកឆ្នោតរបស់អ្នកត្រូវបានទទួលយក នោះឈ្មោះ និងអាសយដ្ឋានរបស់អ្នកអាចនឹងត្រូវបង្ហាញជាសាធារណៈនៅពេលទទួលយក នៅពេលប្រើប្រាស់សម្រាប់ ការបោះឆ្នោត សម្រាប់គោលបំណងនយោបាយ និង ការអនុវត្តច្បាប់។ បើមិនដូច្នោះទេ ទិន្នន័យដែលអ្នក ផ្តល់ជូននៅលើស្រោមសំបុត្រហត្ថលេខារបស់អ្នកនឹង ត្រូវដាក់កំហិតចំពោះមន្ត្រីបោះឆ្នោតរបស់អ្នករហូតដល់ម៉ោង 8:00ល្ងាចនៅថ្ងៃបោះឆ្នោត។ បន្ទាប់ពីពេលនោះ ស្រោមសំបុត្ររបស់អ្នក និងទិន្នន័យនៅលើស្រោមសំបុត្រនោះ ក្រៅពីលេខអត្តសញ្ញាណរបស់អ្នកគឺជាព័ត៌មានសាធារណៈ។ លេខអត្តសញ្ញាណរបស់អ្នកគឺចាំបាច់ដើម្បី ធានាថាសន្លឹកឆ្នោតត្រូវបានប្រគល់ដោយអ្នកបោះឆ្នោតតែម្នាក់ដែលបានដាក់ពាក្យស្នើសុំ។ អ្នកអាចបដិសេធមិនប្រគល់លេខអត្តសញ្ញាណ ប៉ុន្តែការធ្វើដូច្នេះអាចនឹងធ្វើឱ្យសន្លឹកឆ្នោតរបស់អ្នកត្រូវបានបដិសេធ ហើយនឹងមិនអាចឱ្យអ្នកពិនិត្យមើល ស្ថានភាពសន្លឹកឆ្នោតសម្រាប់ពលរដ្ឋអវត្តមានរបស់អ្នកតាមប្រព័ន្ធអនឡាញឡើយ។